KHMER

**រួបរួមគ្នា ដើម្បីជុំរុញ សហគមន៍យើងឲ្យដើរទៅមុខ** (ADVANCING THE COMMUNITY TOGETHER )

**កិច្ច សហការគ្នារវាង អង្គការសមាគមអ្នកស្ម័គ្រចិត្ត (Volunteer Sector) នឹង**
**រដ្ឋាភិបាល អូស្ត្រាលីរដ្ឋខាងត្បូង (South Australian Government)។**
**ខែ ឧសភា ឆ្នាំ២០០៣**

ការ ស្ម័គ្របំរើ គឺជាកិច្ចចូលរួមចំណែក ទាំងស្រុងមួយ ក្នុងជីវិតរស់នៅរបស់ប្រជាជន ដែលរស់ក្នុង រដ្ឋសៅអូស្ត្រាលី។ គេបានពិនិត្យឃើញថា 38% នៃប្រជាជនរស់ក្នុង សៅអូស្ត្រាលី បានចូលរួមសកម្ម ក្នុងសមាគមន៍ អ្នកស្ម័គ្របំរើ។ យើងខ្ញុំរីករាយណាស់ ដែលឃើញសន្ទុះប្រជាជន មានសណ្តានចិត្តចូលរួមសហការគ្នាស្ម័គ្របំរើដូច្នេះ មានក្នុងប្រទេស។ ពួកអ្នកស្ម័គ្រចិត្ត បានធ្វើកិច្ចការច្រើនយ៉ាងមាននៅក្នុងជីវិតយើង, គួរចាំថា បើគ្មានអ្នកស្ម័គ្រចិត្តទេ កិច្ចការបំរើសហគមន៍នានា ការគិតគូររៀបចំផ្សេងៗ ច្បាស់ជានឹង បាត់បង់ ឬមួយក៏ ត្រូវគេកាត់បន្ថយចុះជាច្រើនបំផុតហើយ។ អ្នកស្ម័គ្រចិត្ត បានជួយគ្រប់ផ្នែកកិច្ចការបំរើនានា, ផ្នែកឲ្យយោបល់ នឹងជួយពង្រឹងពង្រីកសតិអារម្មណ៍សង្គមឲ្យរឹតតែខ្លាំងមាំ។ រួបរួមគ្នា ដើម្បីជុំរុញកសាង សហគមន៍យើងឲ្យដើរទៅមុខ : គឺមានន័យថា ការពួតដៃគ្នារវាងអង្គការស្ម័គ្រចិត្ត នឹងរដ្ឋាភិបាល របស់រដ្ឋអូស្ត្រាលីខាងត្បូង គឺជាជំហ៊ានរួមគ្នាមួយយ៉ាងធំ ដើរឆ្ពោះទៅរកជោគជ័យនៃអង្គការស្ម័គ្រចិត្ត រួមនឹង រដ្ឋាភិបាលនៃ រដ្ឋអូស្ត្រាលីខាងត្បូង។ រដ្ឋាភិបាលនេះ បានប្តូរផ្តាច់ ដាក់បញ្ចូលគំរោងបែបផែននេះ រួចហើយ ខំជំរុញភាពសហការគ្នានេះឲ្យ បានទៅមុខជាលំដាប់ តាមរបៀបរបប សមស្រប។

ក្នុងឆន្ទៈសហការគ្នានេះ រដ្ឋាភិបាល ខំប្រឹងស្រាវជ្រាវរាវរកដើម្បីគាំទ្រឧបត្ថម្ភ អង្គការអ្នកស្ម័គ្រចិត្តដែលមានសន្ទុះ ថាមពលខ្លាំង មាំក្នុងចិត្ត , ផ្តូរផ្តាច់ រួចហើយ ស្មោះ ស រីករាយសប្បាយ ជានិច្ចនោះ។ រួបរួមគ្នា ដើម្បីជុំរុញកសាង សហគមន៍យើងឲ្យដើរទៅមុខ នេះ គឺមានន័យថា ខំធ្វើយ៉ាងណាឲ្យអ្នកស្ម័គ្រចិត្តទាំងអស់ បានចូល រួមកំឡាំងពួតដៃគ្នា គ្រប់ស្ថាប័នជាតិ ដែលមានបច្ចុប្បន្នកាល នឹងទៅក្នុងអានាគតកាល ផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណគោរពជាឧិឡារិក ចំពោះអ្នកស្ម័គ្រចិត្តទាំងអស់ ដែលបានចំណាយពេលវេលា ជួយកសាងបង្កើតឯកសារ សហការសមូហភាពគ្នា នេះ ឲ្យចេញជារូបរាងឡើង។ មានជនស្ម័គ្រចិត្តជាង 700 នាក់បានចូលរួម , មានតាំងពី ប្រូក្រាមម៉េណេឃើ នឹង អ្នកស្ម័គ្របំរើពួតដៃជាច្រើនទៀត ដែលរូប ខ្ញុំសូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅ ដ៏ជិតស្និត បំផុត ចំពោះកំឡាំងស្ម័គ្របំរើរបស់ពួកគាត់។

**ឯកឧត្តម ម៉ៃ រ៉ែន** , អ្នកតំណាងរាស្ត្រ
ប្រមុខរដ្ឋ ប្រចាំរដ្ឋអូស្ត្រាលីខាងត្បូង
នឹង រដ្ឋមន្ត្រី អង្គការស្ម័គ្រចិត្ត
**The Hon Mike Rann MP**

May 2003 - ខែ ឧសភា ២០០៣

**សាវតារ ឬក៏ប្រវត្តិ របស់កិច្ចសហការរួម ស្ម័គ្របំរើ** (BACKGROUND TO THE PARTNERSHIP)

នៅក្នុងឆ្នាំ 1999 , អង្គការស្ម័គ្របំរើ(Volunteer Sector) បានបញ្ចេញមតិទាមទារចង់ជួយពង្រីកឲ្យខ្លាំង នឹងធ្វើឲ្យដំណើរការមានប្រយោជន៍ល្អរវាង អង្គការស្ម័គ្របំរើ ប្រទាក់ក្រឡាទៅនឹង រដ្ឋាភិបាលប្រចាំរដ្ឋអូស្ត្រាលីខាងត្បូង។

នៅក្នុងឆ្នាំ 2002 , ប្រមុខរដ្ឋ នឹង រដ្ឋមន្ត្រីទទួលបន្ទុកក្រុមអ្នកស្ម័គ្រចិត្ត, ឯកឧត្តម ម៉ៃ រ៉ែន បានមានប្រសាសន៍ប្រកាសថា គឺជាការព្រមព្រៀងមួយតូចល្មម « កុមប៉ាក់ Compact » ត្រូវតែខំធ្វើឲ្យធំធាត់ឡើង រវាងក្រុមអង្គការស្ម័គ្រចិត្ត នឹង រដ្ឋាភិបាលប្រចាំរដ្ឋនេះ។ ការព្រមព្រៀង “កុមប៉ាក់” ដំណើរការបាន ត្រូវតែ ចាត់ការដោយ ក្រុម “ ភ្នាក់ងារសំខាន់ៗរបស់ កុមប៉ាក់ ឬជាភាសាអង់គ្លេសហៅថា Compact Development Taskforce ” រួមដៃជាមួយ ក្រុមស្ម័គ្រចិត្តសំរាប់បញ្ជូនប្រចាំរដ្ឋ ដែលមានជាភាសាអង់គ្លេសថា State Volunteer Reference Group សមាជិកជាច្រើននៅក្នុង អង្គការស្ម័គ្របំរើទាំងនោះ ដែរ។

អង្គការបំរើនេះ ប្រធានជាតំណាងរាស្ត្រ ឈ្មោះ អ្នកស្រី Ms Jennifer Rankine MP , រួចហើយជា សេក្រេទែ របស់លោកប្រមុខរដ្ឋ ប្រចាំនៅរដ្ឋសភា ផងដែរ។

ក្នុងគំនិតបង្កើតកិច្ចសហការគ្នា ក្រុមរដ្ឋាភិបាលបានបង្កើតអង្គការមួយឈ្មោះ Government Cross Agency Working Party ដើម្បីធ្វើការរួម Compact Development Taskforce ក្នុងការចរចារ , ទទួលកិច្ចព្រមព្រៀង ហើយនឹង រកគោលគំនិត អំពី “ កុមប៉ាក់ ” ដោយមានការប្រជុំដោះស្រាយក្នុងរង្វង់ភ្នាក់ងារអង្គការ ទាំងអស់។

នៅក្នុងរដ្ឋទាំងមូល ការប្រជុំ សួរនាំសុំយោបល់ បានត្រូវគេធ្វើឡើង រវាង ប្រធានអង្គការស្ម័គ្រចិត្ត , អ្នកស្ម័គ្រចិត្តនានា នឹងអ្នកមានរួមចំណែកផ្សេងៗផងដែរ។ គំនិត យោបល់ ផ្សេងៗ ត្រូវបានស្រង់ឡើងក្នុងពេលប្រជុំសុំយោបល់ បញ្ជាក់ច្បាស់ថាសហគមន៍នានា មានជំនឿដើម្បីការចំរើន អង្គការស្ម័គ្របំរើ នឹង រដ្ឋាភិបាលត្រូវតែធ្វើការពួតដៃគ្នា។ គំនិតដែលប្រមូលបានមកគឺត្រូវ គេប្រមូលផ្តុំឡើងដើម្បីធ្វើ ឯកសារនេះឯង។

ចំណងជើង ឯកសារនេះគឺ រួបរួមគ្នា ដើម្បីជំរុញកសាង សហគមន៍យើងឲ្យដើរទៅមុខ មានន័យថា សមូហភាព រវាង អង្គការស្ម័គ្របំរើ នឹងរដ្ឋាភិបាលប្រចាំរដ្ឋអូស្ត្រាលីខាងត្បូង ត្រូវបានគេជ្រើសរើសប្រើវា ដើម្បីឲ្យឆ្លុះបញ្ចាំងនូវ ឯកភាព របស់ប្រជាជនរស់ក្នុងរដ្ឋ សៅអូស្ត្រាលីខាងត្បូង, ដែលមានចិត្តស្ម័គ្របំរើ ធ្វើការក្លាហាន ក្នុងសមូហភាពសហការ ល្អ។

**និយមន័យ** – DEFINITIONS

ក្នុងការបង្កើត ឯកសារនេះ និយមន័យ របស់ពាក្យនានា បានប្រើ ដូច្នេះ ។

**កិច្ចបំរើ មិនយកកំរៃ**– Volunteering

កិច្ចបំរើដោយស្ម័គ្រចិត្តមិនយកកំរៃ ដើម្បីជាប្រយោជន៍ សហគមន៍។ កិច្ចស្ម័គ្របំរើ អាចធ្វើនៅក្នុងរង្វង់សហគមន៍នានា ឬក៏ ជាក្រុម (ឈ្មោះម្យ៉ាងហៅថា Formal Volunteering “ ស្ម័គ្របំរើធម្មតាទូទៅ ” ) ឬក៏ ស្ម័គ្របំរើក្រៅអំពីអង្គការផ្សេងៗ ដូចយ៉ាងជួយអ្នកជិតខាងខ្លួន ម្នាក់ឯង-មិនធម្មតា ក្នុងការទៅជួយទិញអីវ៉ែអីវ៉ាន់ឲ្យគាត់ (Informal Volunteering )។

**អង្គការស្ម័គ្របំរើ** – Volunteer Sector

ក្នុងនោះមាន អង្គការ នឹងក្រុមសហគមន៍ ដែលជួយធ្វើមិនបានកំរៃជាប្រាក់បៀវត្ស ដូចយ៉ាង ក្រុមស្ម័គ្រលត់ភ្លើងឆេះ នឹងក្រុមមិត្តស្រឡាញ់សួនឧទ្យាន ជាដើម។ល។

**ពួកសហគមន៍ ស្ម័គ្រចិត្ត** – Volunteer Community

មានរាប់ទាំងពួកស្ម័គ្របំរើ ជាធម្មតា , មិនធម្មតា , ជាក្រុមជាពួក ម្នាក់ឯង រួមទាំងផ្នែកដែលមានក្នុងអង្គការស្ម័គ្រចិត្តបំរើផង។

**ការងារ សកម្មភាពដែលត្រូវធ្វើ – SCOPE**

សហាការ រួបរួមគ្នា ដើម្បីជំរុញកសាង សហគមន៍យើងឲ្យដើរទៅមុខ គឺជាកិច្ចសន្យាមួយចំពោះប្រជាពលរដ្ឋ ធ្វើឡើងដោយរដ្ឋាភិបាល អូស្ត្រាលីរដ្ឋខាងត្បូង រួមជាមួយនឹង អង្គការស្ម័គ្រចិត្តនានា ដើម្បីបើកចំហរ , ឲ្យមានតំឡាភាព , មាំទាំស្វាហាប់, សហាការគ្នា ធ្វើការជាធ្លុងមួយ។ សាងឡើងនៅលើ សុឆន្ទៈ ពង្រឹងកិច្ចសហាការស្ម័គ្រចិត្តបំរើក្នុងរដ្ឋ អូស្ត្រាលីខាងត្បូង រវាងក្រុមស្ម័គ្រចិត្ត នឹងរដ្ឋាភិបាល។ ការ រួបរួមគ្នា ដើម្បីជំរុញកសាង សហគមន៍យើងឲ្យដើរទៅមុខ ផ្តល់ឧបករណ៍ជាគន្លឹះឲ្យគូភាគីទាំងពីរសហាការធ្វើដំណើរទៅមុខ ជាមួយគ្នាបាន ក្នុងការដោះស្រាយបញ្ហាធំៗដែលប៉ះពាល់លើ កិច្ចបំរើមិនយកកំរៃ នេះ។ វាជាកន្លែងជំរុញគូភាគីទាំងពីរ ឲ្យពិនិត្យឡើងវិញនូវគុណធម៌របស់ខ្លួន(Value) , គោលនយោបាយ នឹងរបៀបចាត់ចែងក្នុងក្រុមខ្លួន ឲ្យកែលំអររកការចំណេញសំរាប់ប្រជាជននៃរដ្ឋ អូស្ត្រាលីខាងត្បូង ព្រមទាំងជំរុញទៅមុខនូវសកម្មភាពអ្នកស្ម័គ្រចិត្ត នឹងអង្គការស្ម័គ្របំរើ។ អង្គការស្ម័គ្របំរើ រួមទាំងរដ្ឋាភិបាល ទទួលស្គាល់នឹងឲ្យតម្លៃ ដល់អ្នកស្ម័គ្រចិត្តមិនចេញមុខម្នាក់ឯង ក្នុងសង្គមយើងដែរ។ ក្នុងពេលដែលធ្វើឯកសារនេះឡើង គឺបានគិតរួមបញ្ចូលគ្រប់សហគមន៍ស្ម័គ្រចិត្តទាំងឡាយដែរ ពីព្រោះវាកើតមកពីកិច្ចសហាការគ្នារវាង រដ្ឋាភិបាល នឹង អង្គការស្ម័គ្របំរើមិនយកលុយ នោះឯងហើយ។

យើងក៏ទទួលស្គាល់ដែរថា រដ្ឋាភិបាល នឹង ពួកសហគមន៍ស្ម័គ្រចិត្ត មានទំនាក់ទនងល្អរវាង ក្នុងក្រសួងរដ្ឋាភិបាលគ្រប់ជាន់ឬគ្រប់ថ្នាក់ , សហាការល្អជាមួយក្រុមហ៊ុនឯកជន ផង នឹង ល្អជាមួយពួកក្រុម សហជីប( Trade Union) ផងដែរ។ ថ្វីបើមិនបានលំអិត ក្នុងកិច្ចសហាការនេះក៏ដោយ, ក៏យើងមិនបានបំភ្លេចសារៈសំខាន់នៃកិច្ចសហាការនេះ នៅតែឲ្យតម្លៃជានិច្ច។

**កាន់ខ្ជាប់នឹងធ្វើឲ្យដើរទៅមុខជានិច្ច កិច្ចសហការគ្នានេះ – TAKING THE PARTNERSHIP FORWARD**

ឯកសារនេះ ផ្តល់នូវ គោលគំនិតជាប្រចាំសំរាប់ប្រាប់រដ្ឋាភិបាល និង អង្គការស្ម័គ្របំរើ អំពីការសំរេចណាមួយ។ ដៃគូរ ទាំងពីរនេះនឹងខំធ្វើយ៉ាងណា ឲ្យបានជោគជ័យដើម្បីជំរុញសង្គមយើងឲ្យចំរើន ទៅមុខជាមួយគ្នា។

អង្គការស្ម័គ្រចិត្ត នឹង រដ្ឋាភិបាលរដ្ឋអូស្ត្រាលីខាងត្បូង ស្ម័គ្រស្មោះជាមួយគ្នាពង្រឹងពង្រីកសង្គម ឲ្យទៅមុខជាលំដាប់តាមរបៀបរបប រយៈពេលវេលា សមស្រប។

- ខំធ្វើយ៉ាងណាឲ្យមានតំណាងមកពីរដ្ឋាភិបាលនឹងពួកតំណាងសហគមន៍ស្ម័គ្រចិត្ត ខំមើលពិនិត្យជំរុញសង្គមជាមួយគ្នា , រក្សាការពារគោលគំនិត នឹង រក្សាទិសដៅ ព្រមទាំងកាលវិភាគល្អ សមស្របផងដែរ។
- ធ្វើការពិគ្រោះទូរទៅ នឹងប្រើការចរចារជាមួយអ្នកស្ម័គ្រចិត្ត ឬអង្គការស្ម័គ្របំរើនានា ក្នុងរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់ដែរ ដើម្បីរកគំនិតថ្មីៗ ទៅមុខរហូត។
- ធ្វើឲ្យមានស្តង់ដារ គំរូល្អ ក្នុងការទាក់ទងគ្នារវាងដៃគូនានា នឹង ពួកសហគមន៍ស្ម័គ្របំរើទាំងអស់ផង។
- ធ្វើយ៉ាងណា ផ្តល់សិទ្ធិឲ្យ អ្នកស្ម័គ្រចិត្តបានចូលរួម ក្នុងរបៀបសំរេចចិត្តគ្រប់កិច្ចការដោះស្រាយផ្សេងៗ។
- ធ្វើឲ្យមានការប្រជុំ ជាញឹកញាប់រវាង រដ្ឋមន្ត្រី/ប្រមុខរដ្ឋ នឹងអ្នកតំណាងមកពីគ្រប់អង្គការស្ម័គ្របំរើទាំងអស់។
- ធ្វើការប្រជុំ១ឆ្នាំម្តង សើរើ រកមើលការចំរើន នឹង រក្សាឲ្យនៅដដែលអ្វីដែលមានប្រយោជន៍ នឹងធ្វើគោលការថ្មីៗ ឬក៏ កាលវិភាគគំរោង ថ្មីៗផងដែរ។
- ត្រូវធ្វើរបាយការណ៍ ជាប្រចាំស្តីអំពី អ្វីៗដែលបានធ្វើ បានបំពេញរួចហើយ នឹងអ្វីដែលជាគោលគំនិតថ្មី ឬក៏ការដាក់ទិសថ្មី។ ដើម្បីធ្វើឲ្យមានការចំរើនជានិច្ច នៃកិច្ចជំរុញសហគមន៍យើងឲ្យចំរើនទៅមុខជាមួយគ្នា នោះ ឯកសារនេះត្រូវតែ កែលំអរ នឹងមើលឡើងវិញជារៀងរាល់ពីរឆ្នាំ ម្តង រួចហើយបន្ថែមដាក់ចូលការសួរសុំយោបល់អំពីរាស្ត្រ តទៀត។

**គោលបំណង វត្ថុបំណង ទូរទៅ** – Overrall Aim

កិច្ច រួបរួមគ្នាជំរុញឲ្យ សហគមន៍យើងដើរទៅមុខ ត្រូវការ រក ៖

- គោរពទទួលស្គាល់ ឲ្យតម្លៃខ្ពស់ដល់កិច្ចស្ម័គ្រចិត្តបំរើមិនយកកំរៃ ដែលមាននៅក្នុងសង្គមរបស់យើង។
- ខំពង្រឹងពង្រីករកផ្លូវទៅមុខ សំរាប់កិច្ចការស្ម័គ្រមានក្នុង  រដ្ឋសៅអូស្ត្រាលី។
- ជួយបង្កើតឲ្យមានទីតាំង គោលគំនិត កម្មវិធីទៅមុខទៀត នៃកិច្ចសហការគ្នានេះ។
- ជួយផ្សាយ ជួយធ្វើឲ្យរីកសាយ ជួយសំរួល កិច្ចស្ម័គ្រចិត្តបំរើមិនយកកំរៃ ដែលធ្វើឲ្យសង្គមយើងចំរើន។

**ចំណង់ ការចង់បាន  នាចុងចប់/ផលប្រយោជន៍** – DESIRED OUTCOMES/BENEFITS

ជាការរីករាយណាស់សប្បាយណាស់ ដែលលទ្ធផលបានមកពី កិច្ចសហការគ្នារវាងរដ្ឋាភិបាលនិងអង្គការស្ម័គ្រចិត្តនេះ វាមាន ច្រើនជំពូកច្រើនយ៉ាង, នាចុងចប់ លទ្ធផលសំរេចបានផ្សេងៗ នឹងបានមកអំពីការប្តូរផ្តាច់ដូចតទៅនេះ ៖

កិច្ចជំរុញទៅមុខ លឿនទៅល្អ នៃការស្ម័គ្របំរើ ៖ ធ្វើយ៉ាងណាឲ្យមានការផ្សព្វផ្សាយ ឲ្យរង្វាន់ នឹងទទួលស្គាល់ ការស្ម័គ្របំរើ សង្គមមិនយកកំរៃ  ក្នុងពេលជាមួយគ្នានោះលើកតំកើងឲ្យតម្លៃល្អ ពន្យល់ឲ្យដឹងឲ្យស្គាល់ គិតដល់ការស្ម័គ្រចិត្តនេះ។

ពន្យល់កែតំរូវឲ្យល្អឡើងវិញ នូវរឿងរ៉ាវណាដែលធ្វើឲ្យបង្អាក់ផ្អាកដំណើរល្អ នៃកិច្ចស្ម័គ្របំរើ៖  ខំរកឲ្យឃើញ នឹងដោះស្រាយជាបន្ទាន់ បញ្ហាដែលធ្វើឲ្យ បង្អាក់ដំណើរការស្ម័គ្រចិត្តបំរើមិនយកកំរៃនេះ។

បង្កើតឲ្យមានឡើង នូវបែបបទ ទំនាក់ទំនង៖  ខំធ្វើយ៉ាងណាពង្រីក នឹងពង្រឹង កែឲ្យរឹតល្អែកិច្ចទាក់ទងគ្នា នឹងផ្តល់ពត៌មានឲ្យគ្នារវាង អង្គការស្ម័គ្របំរើ នឹងក្រសួងរដ្ឋនានា។

រៀបចំការគ្រប់គ្រង នឹងការអនុវត្តន៍៖  ខំកែលំអរ ពង្រឹងគោលនយោបាយក្នុងការសំរេចនានា ដោយយកមកគិតជាធំនូវបញ្ហាដែល មានប៉ះពាល់ដល់ ពួកក្រុមសមាគមន៍ស្ម័គ្រចិត្តនានា ទាំងអស់។

**កំឡាំង សារៈ សន្ទុះ នៃកិច្ចសហការ រួម**  - ESSENCE OF THE PARTNERSHIP

**ចេះចែក រំលែកឲ្យគ្នា នូវ សារៈប្រយោជន៍  ឬ ន័យ** - SHARED VALUES

អង្គការស្ម័គ្របំរើ នឹងរដ្ឋាភិបាល ចែករំលែកឲ្យគ្នា នូវការប្តេជ្ញាចិត្ត ដែលវាជា សរសរទ្រូងរបស់ កិច្ចសហការរួម  ដូចតទៅ ៖

ការបើកចំហមិនលាក់លៀម នឹងតម្លាភាព៖  ក្នុងការទាក់ទងរវាងគ្នានឹងគ្នា ឬក៏ជាមួយប្រជាជន ដែលខ្លួនប្តេជ្ញាបំរើ។

ភាព គោរពគ្នា៖  ការទទួលស្គាល់គ្នា  គោរពគ្នាទៅវិញទៅមក, ទទួលយកយោបល់គ្នា,  ទទួលស្គាល់តួនាទីគ្នា នៅក្នុងសង្គម។

សិទ្ធិស្មើគ្នា៖  ត្រូវតែទទួលស្គាល់ថា  ជនទាំងអស់ មានសិទ្ធិស្ម័គ្របំរើមិនយកកំរៃ នឹងចូលរួមក្នុងសហគមន៍ខ្លួន ដោយមិនគិតថា ជាស្រីឬប្រុស, មិនគិតអាយុ,ជាតិសាសនា,ពិការភាព, ឬថានៅលីវ ឬមានគ្រួសារ, មានផ្ទៃពោះ ឬក៏ចំណូលចំណង់ផ្នែកផ្លូវភេទ។

សញ្ជាតិ កំណើត ៖  រីករាយទទួលស្គាល់ ថា ជនគ្រប់រូប ឯករាជ្យម្ចាស់ការក្នុងការចូលរួមក្នុងសហគមន៍ នឹង សិទ្ធិជាពលរដ្ឋ។

ការធ្វើឲ្យសហគមន៍មានភាពរឹងមាំ ៖  ទទួលស្គាល់ថា ប្រយោជន៍ធំថ្ងៃក្រោយរបស់សង្គម  នឹងអនាគត សង្គម សេចក្តីត្រូវការនៃ សង្គម ត្រូវតែគេយកមកគិតជាមុន  ក្នុងពេលចាត់ការបញ្ហាអ្នកស្ម័គ្រចិត្តបច្ចុប្បន្ន។

**ចេះចែករំលែកឲ្យគ្នា រួម គ្នា នូវ គោលការណ៍ សីលធម៌**  - SHARED PRINCIPLES

កិច្ចការជុំរុញសហគមន៍យើងឲ្យទៅមុខរួមគ្នា  ឈរលើ គោលសីលធម៌ ដូចតទៅ ៖

**សហប្រតិបត្តិការ  រួមគ្នា ,  សួរសុំយោបល់គ្នា , នឹងគាំទ្រគ្នា៖**  ដៃគូរ ម្នាក់ៗដឹកនាំធ្វើការងាររៀងខ្លួនក្នុងភាពចំហរ មិនលាក់លៀម នឹង ស្តាបនាជួយគ្នា ជានិច្ច  ដោយគោរពសិទ្ធិប្រជាជនជាធំ,  ផ្តល់សិទ្ធិឲ្យសួរ ឲ្យចោទជាសំនួរ តវ៉ាគ្នា(Challenge) នឹងចែកចាយឲ្យ

គ្នាការរីកចំរើនទៅអ្នកស្ម័គ្រចិត្ត គ្រប់រូប។ ផ្តល់ពត៌មានឲ្យគ្នាទៅវិញទៅមក, សួរនាំគ្នាទៅវិញទៅមកជាភាតរភាព, គាំទ្រគ្នាទៅវិញទៅមក ដែលជាគ្រឹះដំបូងបំផុត សំរាប់សង្គមទូទៅ។

**ឯករាជ្យ ភាព** - Independence

រដ្ឋាភិបាលសៅអូស្ត្រាលី មានតួនាទីជាអ្នកសំរេចដើម្បីប្រយោជន៍ចម្បងរបស់ប្រជាជន រដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់ រីឯអង្គការស្ម័គ្របំរើមានភារៈកិច្ចទទួលខុសត្រូវតាមតួនាទីរបស់ខ្លួនដែលបានទទួលឬដែលគេបានចែកឲ្យធ្វើ។ ដៃគូម្នាក់ៗ មានសិទ្ធិតវ៉ាឲ្យយោបល់ ក្នុងកាងារដោយសេរី ឯករាជ្យ ម្ចាស់ការ។

**ឯករាជ្យ ភាព** ៖ សកម្មភាពរបស់គូភាគគីមួយៗ អាចផលលំបាកប៉ះពាល់ដល់ ការងារដៃគូមួយផ្សេងទៀត ទោះជាជំពោះឬមិនជំពោះក្តី, ពីព្រោះ ទាំង២នាក់ធ្វើការដើម្បីផលប្រយោជន៍រួមតែមួយ នឹងនៅក្នុងតំបន់ រដ្ឋតែមួយ គឺសំរាប់ប្រជាជនដែលនៅក្នុងរដ្ឋសៅអូស្ត្រាលីតែម្តង។ គូភាគី មានឯងខ្លួនផ្សេងៗគ្នា តែសហការគ្នា រួចសម្បាច់គ្នា ដើម្បីសំរេចគោលបំណងរួមទាំងអស់គ្នា។

**មេដឹកនាំខ្លាំងពូកែ-នឹង-មានសកម្មភាពល្អត្រូវ** ៖ ក្រៅអំពីធ្វើសកម្មភាពឲ្យសមស្របទៅនឹងសេចក្តីត្រូវការដែលមានកើតឡើងនោះ គូភាគីដែលសហការគ្នានេះ ត្រូវតែមើលឲ្យបានឆ្ងាយ ធ្វើឲ្យបានប្រយោជន៍ រួមគ្នារកសកម្មភាពថ្មី នឹងចំឡើយថ្មីៗដែរ។

**ការចេះ ទទួលខុសត្រូវ** - Accountability

អង្គការស្ម័គ្របំរើ នឹង រដ្ឋាភិបាលប្រចាំរដ្ឋអូស្ត្រាលីខាងត្បូង ត្រូវតែមានតំឡាភាពក្នុងការដឹកនាំ, ប្រើរបៀបដឹកនាំដែលត្រឹមត្រូវល្អមានសុភាវិនិច្ឆ័យ, ត្រូវមានចារឹកមារយាទល្អ ខ្ពស់, ធ្វើការទាក់ទងគ្នាដោយស្មោះចំពោះមិនលាក់លាម ដើម្បីបំរើប្រជាជនរបស់ខ្លួន។ ម្នាក់ៗ ត្រូវតែរាយការណ៍ នឹង ចេះទទួលខុសត្រូវ ធ្វើឲ្យបានការ នឹងមានគុណភាពល្អផងដែរ។

**ការទទួល ជនជាតិនានា ឲ្យមកចូលរួម, នឹងបើកទទួលសគមន៍នានាឲ្យជួយ**៖ កិច្ចស្ម័គ្របំរើមាននៅគ្រប់ទិសទី ស្រឡាញ់រួចចូលចិត្តកីឡា, សិល្បៈនានា, គោរពស្រឡាញ់បរិដ្ឋាន, យុត្តិធម៌, សុខភាព, សង្គមកិច្ច, ការសិក្សា, ក្រុមជួយសង្គ្រោះ,សាសនា, នឹងកេត្តណៈភ័ណ្ឌជាតិ ជាច្រើន។ ប្រជាជនជាច្រើន គ្រប់ភេទ មិនថាក្មេងចាស់ ជរាពិការ គ្រប់សាសនា មិនចំពោះមានចិត្តចង់ជួយសង្គមរបស់យើង ទៅតាមដែលលទ្ធភាពមាន។ ការស្ម័គ្របំរើមិនបានលុយជាកំរៃ , រួចវាអស់សោហុយ ថែមទៀតផង ។

**តស៊ូធ្វើការងារស្ម័គ្របំរើ** – COMMITMENT TO ACTION

ទាំង២នាក់ រដ្ឋាភិបាល នឹង អង្គការស្ម័គ្របំរើ ប្តូរផ្តាច់ទទួលស្គាល់សេចក្តីត្រូវការ នឹងត្រូវតែគាំទ្រ នូវគុណសម្បត្តិ ព្រមទាំងសីលធម៌ ដែលមានក្នុង ការរួបរួមគ្នាជុំរុញសង្គមឲ្យទៅមុខទាំងអស់គ្នានេះ ដោយតស៊ូប្តូរផ្តាច់ធ្វើការងារ មិនរាថយ។ ដៃគូធ្វើការខុសប្លែកៗគ្នា ក៏ប៉ុន្តែ ជាមួយគ្នា ជួយផ្សាយលើកតំកើង នឹង សំរួល ឲ្យល្អដល់ ការស្ម័គ្របំរើមានក្នុងរដ្ឋសៅអូស្ត្រាលី។

**ការចេះ ទទួលខុសត្រូវ** - ACCOUNTABILITY

**ចេះចែករំលែក ការងារ ករណីយកិច្ច គ្នាឲ្យធ្វើ**

- តស៊ូប្តូរផ្តាច់ផ្តល់កិត្តិយសលើសេចក្តីទុកចិត្តរបស់ប្រជាជន នៃរដ្ឋអូស្ត្រាលី។
- ពង្រីកការទទួលខុសត្រូវ នឹង មើល ពិនិត្យ រាយការណ៍ ជាប្រចាំ។
- ប្តូរផ្តាច់ធ្វើឲ្យមានតំឡាភាព បើកចំហ គ្មានលាក់លៀម ក្នុងការរួមការងារ នឹងបំរើប្រជាជន។

**ការទាក់ទងធ្វើបណ្តាញការងារ** – ACCOU

**ចេះចែករំលែក ការងារ គ្នាបំពេញ ករណីយកិច្ច**

- បង្កើតឲ្យមានបណ្តាញទាក់ទង, ជួយបំពេញការងារ នឹង ជឿជាក់លើអ្នកស្ម័គ្រចិត្តក្នុងរដ្ឋនឹងក្នុងអង្គការនានា។
- ចាត់ចែង, គាំទ្រ, នឹង ទាក់ទងគ្នាធ្វើយ៉ាងណាឲ្យអ្នកស្ម័គ្រចិត្តជួយបានតាមកំឡាំងសទ្ធាដែលអាចជួយបានផង។
- ចែករំលែកគំនិត ពត៌មាន ពង្រីកការយល់ដឹង នឹងរកឲ្យឃើញរួមគ្នានូវអ្វីៗដែលត្រូវធ្វើមុនគេនោះ។

- ត្រូវតែគោរព  សិទ្ធិដៃគូ ចំពោះពត៌មានខ្លះ ដែលត្រូវលាក់ការ។
- ចែករំលែកឲ្យគ្នានូវ ពត៌មាន, គំនិតអ្វីដែលធ្វើឲ្យសង្គមចំរើន, ពង្រីកកិច្ចស្ម័គ្រចិត្ត នឹងទទួលស្គាល់អ្នកស្ម័គ្រចិត្ត។

**ក្រុមអង្គការស្ម័គ្របំរើ** – Volunteer Sector

- ចេះចែកពត៌មានឲ្យគ្នា , ចេះលើកទឹកចិត្តគ្នា នឹងខំរកអ្នកស្ម័គ្រចិត្ត  នឹងខំរកកិច្ចការនានា។
- និយាយទាក់ទងជាមួយពួកស្ម័គ្រចិត្ត ធ្វើយ៉ាងណាឲ្យគំនិតពួកគាត់ត្រូវគេបានដឹងបានឮ នឹងពន្យល់ប្រាប់វិញបាន។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ត្រូវផ្តល់ពត៌មានឲ្យក្រសួងរដ្ឋទទួលបន្ទុកអ្នកស្ម័គ្រចិត្ត នឹងផ្សាយឲ្យដឹងអំពីលុយរដ្ឋជួយដល់ក្រុមអ្នកស្ម័គ្រចិត្ត។
- សំរួល ពង្រីកឲ្យធំ កិច្ចស្ម័គ្របំរើ  នឹង ចែកគ្នាដឹងពត៌មាន  នឹងចែករំលែកឲ្យគ្នា អំពីគំនិតល្អៗ ។
- ត្រូវប្រាប់ក្រុមអង្គការស្ម័គ្រចិត្ត នឹងពន្យល់ឲ្យដឹង អំពី អ្វីៗដែលមានឡើងជាបញ្ហា នឹងការរីកដាលទៅមុខ។
- ត្រូវបកប្រែ ត្រូវផ្សាយឲ្យដឹង ត្រូវដាក់ឲ្យច្បាស់ៗ  ពាក្យសុំត្រូវមានជានិច្ច នឹងឲ្យមានគ្រប់ភាសាផង។

**សមធម៌ ភាពស្មើគ្នា  នឹង ការរាប់បញ្ចូលផងដែរ** – EQUITY AND INCLUSIVENESS
**ចេះចែករំលែកឲ្យគ្នា  បំពេញ ករណីយកិច្ច**

- ត្រូវចែកជំនួយរបស់រដ្ឋឲ្យបានគ្រប់ៗ អង្គការស្ម័គ្រចិត្តផង។
- ផ្តល់សិទ្ធិឲ្យប្រជាជនគ្រប់ជាន់ថ្នាក់ គ្រប់ស្រទាប់សញ្ជាតិ បានចូលជួយ តាមដែលគេចូលចិត្ត ចង់ជួយ។
- ត្រូវគោរពសេចក្តីត្រូវការ របស់ប្រជាជនដែលមកអំពីគ្រប់ស្រទាប់ សញ្ជាតិ នឹងសាសនា ពេលឲ្យជំនួយ។
- ត្រូវទទួលស្គាល់ ថា  អ្នកស្ម័គ្រចិត្ត មានមកពីគ្រប់មជ្ឈដ្ឋាន នឹងឲ្យតម្លៃ ព្រមទាំងគោរព ការស្ម័គ្ររបស់គេ។
- ត្រូវរកឲ្យឃើញ ថាតើអ្វីដែលជាការ បង្អាក់ នាំឲ្យទើស ចូលមិនរួច របស់ ៖
  - ជនជាតិដើម អាប៊ូរីជីនី។
  - ប្រជាជន មិននិយាយភាសាអង់គ្លេសពីកំណើត។
  - ជនមានពិការភាព។
  - ប្រជាជនដែលក្រីក្រ ខ្វះខាត នឹង ត្រូវខំធ្វើយ៉ាងណាបើកចំហឲ្យគាត់ចូលមកជួយ បានផង។
- ទទួលស្គាល់ការ លំបាក សំរាប់អ្នកស្ម័គ្រចិត្ត ដែលមាននៅក្នុងជនបទ ទីឆ្ងាយៗដាច់ស្រយាល នឹង លើទឹកដីជនជាតិដើម(Traditional Lands) ផងដែរ។

**ក្រុមអង្គការស្ម័គ្រចិត្ត** - Volunteer Sector

- ផ្ដល់សិទ្ធិឲ្យ ប្រជាជនដែលដែលមានពិការភាព នឹងមកពីគ្រប់ស្រទាប់សញ្ជាតិ ផាសា បានចូលមកជួយក្នុងក្រុមស្ម័គ្រចិត្ត នោះផង ។
- ប្រស្រ័យទាក់ទង តភ្ជាប់ ទំនាក់ទំនង ប្រជាជនគ្រប់ស្រទាប់ គ្រប់សញ្ជាតិ គ្រប់ភាសា ដើម្បីពង្រីកគំនិតសហការជួយគ្នា រួមគ្នាស្ម័គ្រចិត្តនេះផង។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ទទួលស្គាល់ថា ជនជាតិមួយៗ មានការយល់ដឹងផ្សេងៗគ្នា ទៅលើនិយមន័យរបស់ពាក្យ អ្នកស្ម័គ្រចិត្ត នឹងក្រុមអង្គការស្ម័គ្រចិត្ត ដូច្នេះត្រូវប្រើធនធាន ធ្វើយ៉ាងណា ឲ្យបានជ្រួតជ្រាបដឹងត្រឹមត្រូវល្អវិញ។
- មុននឹងធ្វើច្បាប់ត្រូវតែ ពិគ្រោះជាមួយជនជាតិដើម នឹងជនជាតិនានាដែលនិយាយភាសាផ្សេងៗ ខ្លាចក្រែងច្បាប់ថ្មីនោះមានការប៉ះពាល់ ដល់សកម្មភាពស្ម័គ្រចិត្តរបស់ពួកគាត់។

**តំរូវការ ផ្នែកនយោបាយ និង ច្បាប់ទម្លាប់** – POLICY AND LEGISLATION DEVELOPMENT

**ចេះចែករំលែកឲ្យគ្នា បំពេញភារៈកិច្ចរួមគ្នា**

- រកឲ្យឃើញ នឹងឆ្លើយឲ្យត្រូវចំ បញ្ហាដែលបង្អាក់ពន្យឺត កិច្ចការស្ម័គ្រចិត្តនានា ជាទូទៅ។
- ពង្រីកពង្រឹង នយោបាយ នឹងធ្វើសេចក្ដីណែនាំ ពាក់ព័ន្ធកិច្ចស្ម័គ្រចិត្ត រួចហើយត្រូវសើរើ ឲ្យបានញឹកញយ។
- បញ្ចូលសមាជិក ទាំងពីរក្រុមឲ្យមក ចាត់ចែងធ្វើប្លង់ សំរាប់ក្រុមស្ម័គ្រចិត្ត។

**ក្រុមអង្គការស្ម័គ្រចិត្ត** – Volunteer Sector

- បង្កើតគំនិតទាក់ទងជាមួយរដ្ឋាភិបាល ដើម្បីធ្វើគោលនយោបាយ ឲ្យសមស្រប។
- ចូលរួមឲ្យសកម្មជាមួយរដ្ឋាភិបាល ក្នុងការពិគ្រោះរាវរក នឹងបង្កើតគោលនយោបាយថ្មីៗ ឲ្យសមស្រប។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ជួប សួរនាំ សុំយោបល់គ្រប់អង្គការស្ម័គ្រចិត្ត មុនធ្វើគំរោងធ្វើច្បាប់ ដែលមានការប៉ះពាល់កិច្ចស្ម័គ្រចិត្ត។
- ផ្ដល់ពត៌មាន ឲ្យគំនិត យោបល់ឱវាទ នឹងធ្វើការជាមួយ ក្រុមអង្គការស្ម័គ្រចិត្ត ក្នុងការកែប្រែច្បាប់ ឬក៏ធ្វើគំរោងច្បាប់ថ្មីៗ។

**ការជ្រើសរើសបុគ្គលិក នឹង រក្សាទុក** – RECRUITMENT AND RETENTION

**ចែករំលែកឲ្យគ្នា បំពេញភារៈកិច្ចរួមគ្នា**

- ផ្សព្វផ្សាយ ឲ្យតម្លៃ ដល់អ្នកស្ម័គ្រចិត្តដែលជួយធ្វើកិច្ចការ, ជួយឲ្យយោបល់គំនិតនានា, កែលំអរកិច្ចការងារ, ទ្រទ្រង់សង្គមប្រជាជន, មិនថា តែគាត់ធ្វើការងារនោះៗ ជាក្រុម ជាពួក ឬក៏ ជួយម្នាក់ឯង ឡើយ។
- ជួយជំរុញ ជួយលើកស្ទួយ យុវជន ឲ្យបានចូលក្នុងការស្ម័គ្រចិត្ត។
- អរគុណ សរសើរ ក្រុមនិយោជក់/ថៅកែ ដែលបានឲ្យកម្មករខ្លួន មកចូលជួយស្ម័គ្រចិត្ត។
- ដាច់ខាតមិនត្រូវ យកអ្នកស្ម័គ្រចិត្ត មកធ្វើការជំនួស(Substitute )កម្មករធ្វើការមានប្រាក់បៀវត្សសោះឡើយ។
- ទទួលស្គាល់ នឹង ឲ្យរង្វាន់ តួនាទីសំខាន់ របស់អ្នកស្ម័គ្រចិត្ត ដែលមានក្នុងរដ្ឋការ នឹងក្នុងក្រុមអង្គការស្ម័គ្រចិត្ត។

**ក្រុមអង្គការស្ម័គ្រចិត្ត** - Volunteer Sector

- ផ្តល់ឱកាសឲ្យជនគ្រប់រូប ចូលជួយតាមអាច តាមចំណង់ តាមទិសដៅអង្គការដែលគេស្គាល់ចង់ធ្វើ។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ទទួលស្គាល់ ផ្តល់សិទ្ធិ ឲ្យអង្គការនានានោះ ជ្រើសរើសយក បុគ្គលិកដែលជាអ្នកស្ម័គ្រចិត្តមកធ្វើការតាមចំណង់។
- ឧបត្ថម្ភ , លើទឹកចិត្ត  នឹង ពង្រីក កិច្ចស្ម័គ្របំរើឲ្យបានច្រើនៅក្នុងសហគមន៍ជាតិ។
- ផ្តល់កន្លែងឲ្យអ្នកស្ម័គ្រចិត្ត ធ្វើនៅក្នុងក្រសួងរដ្ឋាភិបាល តាមដែលអាចធ្វើបាន។

**អោក្សាននុក** – RESOURCES

**ចែករំលែកឲ្យគ្នា  បំពេញភារះកិច្ចរួមគ្នា**

- ខំចាត់ការឲ្យបានត្រឹមត្រូវ ផ្នែកហិរញ្ញវត្ថុ លុយកាក់ នឹង ចេះទទួលខុសត្រូវខ្លួនឯង។
- ធ្វើឲ្យមាន សហាការមកអំពី ប្រជាជន, គ្រប់ក្រសួងរដ្ឋបាល, ក្រុមហ៊ុនឯងជន, គ្រឹះស្ថានសិក្សា នឹងសារពត៌មាន។
- ទទួលស្គាល់ទាំងក្រុមស្ម័គ្រចិត្តតូច មកពីទីជនបទ នឹង ក្រុមប្រជាជនភាគតិចផងដែរ។

**ក្រុមអង្គការស្ម័គ្រចិត្ត** - Volunteer Sector

- ត្រូវឲ្យសមស្របនឹងសេចក្តីណែនាំរបស់រដ្ឋាភិបាល,ឲ្យត្រូវច្បាប់នឹងឲ្យត្រូវផ្នែករដ្ឋបាលដែរ ដើម្បីសុំលុយឧបត្ថម្ភ។
- លើកទឹកចិត្តក្រុមអង្គការស្ម័គ្រចិត្តឲ្យធ្វើការឲ្យជិតស្និតកុំឲ្យមានជាន់គ្នាលើកិច្ចបំរើ នឹងប្រើពលកម្មឥតប្រយោជន៍។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ធ្វើឲ្យមានលុយកាក់គ្រប់គ្រាន់ នឹងមានបុគ្គលិកជាប្រចាំ នៅពេលណាស្ម័គ្របំរើនៅក្នុងក្រសួងរដ្ឋាភិបាល។
- សហាការជាមួយអង្គការស្ម័គ្របំរើ ដើម្បីសើរើ កែប្រែ សេចក្តីណែនាំ នឹងរបៀបធ្វើកិច្ចការ ឲ្យរឹតតែប្រសើរឡើង ឲ្យច្បាស់លាស់ , ឲ្យស្មើភាពគ្នា  នឹងឲ្យយល់ព្រមទាំងអស់គ្នា។

**ការពារគ្រោះថ្នាក់** – RISK MANAGEMENT

**ចែករំលែកឲ្យគ្នា  បំពេញភារះកិច្ចរួមគ្នា**

- ពិនិត្យមើលជាប្រចាំ ក្រែងមានច្បាប់ប៉ះពាល់លើអ្នកស្ម័គ្រចិត្ត។
- សហាការគ្នា ដើម្បីដោះស្រាយបញ្ហាធានារ៉ាប់រង កុំឲ្យមានការធ្ងន់ធ្ងរលើសហគមន៍អ្នកស្ម័គ្របំរើ។

**ក្រុមអង្គការស្ម័គ្រចិត្ត** - Volunteer Sector

- ចេះទទួលខុសត្រូវ ការពារកុំឲ្យគ្រោះថ្នាក់ នឹងលើកទឹកចិត្តក្រុមអង្គការឲ្យពន្យល់គ្នាម្នាក់ៗ ឲ្យចេះប្រយ័ត្ន នឹងឲ្យចេះដឹងទទួលខុសត្រូវ ខ្លួនឯង។
- ចូលសិក្សា រៀនសូត្រ ទទួលដំណឹងអំពី របៀបការពារគ្រោះថ្នាក់ នឹង បញ្ហាធានារ៉ាប់រង ឲ្យដែរ។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ផ្សព្វផ្សាយ ចែកចាយ ពន្យល់ពត៌មានស្តីពី ការមានជាប់ជំពាក់ត្រូវសងគេ, បញ្ហាធានារ៉ាប់រង, ដោះស្រាយគ្រោះថ្នាក់ពាក់ព័ន្ធនឹងអ្នកស្ម័គ្រចិត្ត ហើយនឹងរបៀបចាត់ការដឹកនាំ អង្គការអ្នកស្ម័គ្របំរើនោះ។
- ធ្វើឲ្យមាន ច្បាប់ការពារ នឹង ចេញសេចក្តីណែនាំ ដើម្បីការពារ គាំទ្រ អង្គការស្ម័គ្រចិត្តដែលគេទទួលស្គាល់ បើ អាចធ្វើទៅបាននោះ។

**កិច្ចការហាត់ពត់លត់ដំ**– TRAINING

**ចែករំលែកឲ្យគ្នា បំពេញភារៈកិច្ចរួមគ្នា**

- ទទួលស្គាល់សេចក្តីត្រូវការរបស់អ្នកស្ម័គ្រចិត្ត នឹងជនដែលចាត់ចែងកម្មវិធីអ្នកស្ម័គ្រចិត្ត ដើម្បីធ្វើឲ្យបានឲ្យមានស្នៀល ជំនាញល្អ ដើម្បីផ្តល់កិច្ចបំរើមានគុណភាពច្បាស់លាស់មកវិញ។
- ទទួលដឹងឮ ស្គាល់ថា កិច្ចហាត់ពត់លត់ដំខ្លះ ត្រូវការច្បាប់ការពារ, នឹងកិច្ចហាត់រៀនចំណេះជំនាញខ្លះត្រូវការរៀនសូត្រឲ្យគ្រប់ឲ្យឯល់ជំរៅទើបប្រើការបានតាមខ្នាតបន្ទាត់សន្តិសុខ នឹងតាមខ្នាតផ្នែកឧស្សាហកម្ម ល្អ ប្រើបាន។

**ក្រុមអង្គការស្ម័គ្របំរើ** - Volunteer Sector

- រកឲ្យឃើញ នឹងដាក់ឲ្យប្រើឲ្យធ្វើរបៀបហាត់រៀន , ឲ្យសមប្រកបត្រូវចំសេចក្តីត្រូវការ នឹងចំគោលបំណងអង្គការត្រូវចិត្តពួកក្រុម នឹង ចំសកម្មភាពអ្នកស្ម័គ្រចិត្ត។

**រដ្ឋាភិបាល រដ្ឋអូស្ត្រាលីខាងត្បូង** – South Australian Government

- ដឹង នឹងទទួលស្គាល់ថា អ្នកស្ម័គ្របំរើត្រូវឲ្យមានការហាត់ពត់លត់ដុំឲ្យចេះមានចំណេះឲ្យច្រើន ដើម្បីបំពេញកិច្ចបំរើរបស់ខ្លួន ឲ្យមានប្រសិត្ថិភាព។
- បង្ករបង្កើតឲ្យមានច្រើនយ៉ាងផ្នែកបង្ហាត់បង្ហាញត្រៃណឹង គ្រប់កន្លែង គ្រប់ស្ថាប័នរដ្ឋ សំរួលច្បាប់ដែលមានប៉ះពារលើការស្ម័គ្របំរើ ឬក៏ ក្រុមអង្គការស្ម័គ្រចិត្តនានា។

**ប្រមុខរដ្ឋ នៃរដ្ឋអូស្ត្រាលីខាងត្បូង** រួមជាមួយនឹង **អ្នកតំណាងអង្គការ**ទាំងអស់ខាងក្រោមនេះ សហការគ្នា តស៊ូប្តូរផ្តាច់ ជំរុញសហគមន៍យើងឲ្យដើរទៅមុខរួមគ្នា ៖ មានន័យថា សហការគ្នារវាង អង្គការស្ម័គ្របំរើ នឹង រដ្ឋាភិបាលអូស្ត្រាលីរដ្ឋខាងត្បូង។

**ឯកឧត្តម ម៉ៃ រ៉ែន** , អ្នកតំណាងរាស្ត្រ

**The Hon Mike Rann MP**

**ប្រមុខរដ្ឋ នឹង រដ្ឋមន្ត្រី នៃអ្នកស្ម័គ្រចិត្ត**

Aboriginal & Torres Strait Islander Commission-អគ្គស្នងការ អាបូរីយីនី នឹងពួកកោះ ធ័ររេះត្រៃដ។

Association of Community Service Organisations-សមាគម អង្គការអ្នកបំរើសង្គម។

Association of Major Community Organisations-សមាគម នៃពួក អង្គការធំៗ

Australasian Association of Volunteer Administrators-សមាគមគ្រប់គ្រង អ្នកស្ម័គ្រចិត្ត អូស្ត្រាឡេស៊ីយ៉ា

Australian Red Cross (SA Division) – កាកបាទក្រហម អូស្ត្រាលី (ប្រចាំតំបន់ សៅអូស្ត្រាលី )

Business SA-ប៊ីស៊ីណេស អេស អេ

Community Volunteer-ខំមុយនីធី វ៉ូលុនធា។

Council on the Ageing SA - អគ្គស្នងការ ក្រុមប្រឹក្សា ស្ដីពី ជនជរាពិការ។

Country community representative-ក្រុមតំណាង សហគមន៏ អ្នកនៅតាមជនបទ។

Fleurieu Volunteer Resource Centre-ក្រុមពួក អ្នកស្ម័គ្រចិត្ត នៅ ហ្វ្លឺរីយើ

Friends of Parks-មិត្រអ្នកស្រឡាញ់ការពារ សួនឧទ្យាន នឹង ព្រៃព្រឹក្សា។

Local Government Community Services Association-សមាគមកិច្ចបំរើសង្គម របស់រដ្ឋាភិបាលលូកាល។

Meals on Wheels (SA)-ក្រុមដឹកម្ហូប ជូនអ្នកពិការ នឹង ជនចាស់ជរា។

Multicultural Communities Council of SA-ក្រុមសមាគម ពហុវប្បធម៌ ប្រចាំនៅ សៅអូស្ត្រាលី។

Northern Volunteering – ក្រុមមានចិត្ត ស្ម័គ្របំរើ នៅប៉ែកខាងជើង។

Recreation SA - រីក្រេអេសិន អេស អេ។

Returned & Services League-សមាគម ទាហ៊ានចាស់។

Royal Association of Justice of SA-សមាគម រ៉ូយ៉ៃយ៉ាល នៃអ្នកច្បាប់ នៅសៅអូស្ត្រាលី។

South Australian Association of State School Organisation-សមាគមសាលារដ្ឋនៅសៅអូស្ត្រាលី។

South Australian Council of Social Services-សៅអូស្ត្រាលី ខោនសីល នៃកិច្ចការបំរើសង្គម។

South Australian Museum-សារមន្ទីរជាតិ នៅសៅអូស្ត្រាលី។

South Australian Volunteer Fire Brigades Association-សមាគមអ្នកស្ម័គ្របំរើក្រុមលត់អគ្គីភ័យ អេសអេ

Sport SA-ស្ពត អេស អេ។

State Heritage Authority-ស្តេត ហេរីថេច អូថូរីធី។

Surf Life Saving SA-សើរ ឡៃ្វ សេ វីង អេស អេ។

United Trades and Labor Council- យូណៃធិត ត្រេដ នឹង ឡេប័រ ខោនសីល។

Volunteering SA- វ៉ូឡិនធា អេស អេ។

Youth Affairs Council of SA- យូស អាហ្វែ ខោនសីល អេស៕